# សេចក្តីជូនដំណឹង

ភ្នំពេញ, ថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៣

## សេចក្តីជូនដំណឹង លេខ ១១ សក.អក. ៩៣
## ស្តីពី ការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស

* * * *

ក្រសួងសង្គមកិច្ច និង ការងារ សូមជំរាបដល់ម្ចាស់រោងចក្រ សហគ្រាស ឧស្សាហកម្ម ពាណិជ្ជកម្ម សិប្បកម្ម កសិកម្ម សេវាកម្ម ទាំងអស់អោយបានជ្រាបថា :

ដើម្បីអនុវត្ត មាត្រា ១៩ មាត្រា ២០ មាត្រា ២១ មាត្រា ២២ និង មាត្រា ២៣ នៃច្បាប់ការងារអោយ បានត្រឹមត្រូវ និង ទទួលលទ្ធផលល្អ ក្រសួង សូមម្ចាស់សហគ្រាស គ្រឹះស្ថាន រោងចក្រ ទាំងអស់ខាងលើ អនុវត្តដូចតទៅ :

១- នាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន រោងចក្រដូចពោលខាងលើ ដែលមានប្រើអ្នកស៊ីឈ្នួល យ៉ាងតិច ១០ នាក់ឡើងទៅ ត្រូវរៀបចំអោយមានបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសមួយជាដរាប ។

២- បទបញ្ជាផ្ទៃក្នុង ត្រូវអនុវត្តបទបញ្ញត្តិទូទៅ នៃច្បាប់ការងារតាមប្រភេទសហគ្រាស និងវិធាន ទូទៅនៃការងារ ដែលស្តីពីផ្នែកសកម្មភាពនៃសហគ្រាសជាអាទិ៍ បទបញ្ញត្តិទាក់ទងនិងល័ក្ខខ័ណ្ឌទទួលធ្វើការ ការគិត និង ការប្រើ ប្រាស់ឈ្នួល និង កំរៃបន្ទាប់បន្សំទាក់ទងនិងនាវកាលិកធម្មជាតិ ពេលម៉ោងធ្វើការ ពេលសំរាក និង ការឈប់សំរាកការអោយដំណឹង មុន វិធានការ អនាម័យ និង សន្តិសុខ អ្នកស៊ីឈ្នួល កាតព្វកិច្ចអ្នកស៊ីឈ្នួល និង ទណ្ឌកម្មដែលនិងអាចតំរូវលើអ្នកស៊ីឈ្នួល ដូចមានគំរូជាឧបសម្ព័ន្ធ នៃ សេចក្តីជូនដំណឹងនេះ ។

៣ - បទបញ្ជាផ្ទៃក្នុង ត្រូវរៀបចំឡើងដោយនាយកសហគ្រាស ក្រោយពីបានពិគ្រោះ និង តំណាងបុគ្គលិក ក្នុងរយៈពេលបីខែបន្ទាប់ពីថ្ងៃបើកសហគ្រាស ឬ ក្នុងរយៈពេលបីខែក្រោយពីការប្រកាសអោយប្រើច្បាប់ ការងារ ឬ សេចក្តីជូនដំណឹងនេះប្រសិនបើសហគ្រាសកើតរួចមកហើយ ។

ក្រោយពេលកសាងរួចហើយនាយកសហគ្រាសត្រូវបញ្ជូនបទបញ្ជាផ្ទៃក្នុងនោះចំនួនពីរច្បាប់ដោយមានភ្ជាប់ទាំងមតិយោបល់ជាលាយលក្ខណ៍អក្សររបស់តំណាងបុគ្គលិកផង ទៅសុំចុះទិដ្ឋាការអំពីអធិការការងារ មុននឹងដាក់អោយប្រើប្រាស់ជាផ្លូវការ ។

សហគ្រាសទាំងអស់នៅភ្នំពេញ ត្រូវបញ្ជូនបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនទៅនាយកដ្ឋានអធិការកិច្ចការងារ នៃក្រសួងសង្គមកិច្ចនិងការងារ ស្ថិតនៅផ្ទះលេខ ២៨ ផ្លូវលេខ ១៨៤ សង្កាត់ជ័យជំនះ ខ័ណ្ឌដូនពេញ ក្រុងភ្នំពេញ ចំណែក សហគ្រាសនៅតាមខេត្ត ក្រុង ត្រូវជូនទៅអធិការដ្ឋានសង្គមកិច្ច និង ការងារ ខេត្ត ក្រុង នៃមូលដ្ឋានខ្លួនដើម្បីស្នើសុំចុះទិដ្ឋការ ។

៤ - បើបទបញ្ជាផ្ទៃក្នុងមានការខ្វះចន្លោះ អធិការការងារ និង ជូនដំណឹងអោយម្ចាស់សហគ្រាសយក ទៅកែសំរួលអោយសមស្របឡើងវិញ ។

ក្រោយពីបានទទួលដំណឹងនេះ នាយកសហគ្រាសត្រូវធ្វើការកែសំរួលឡើងវិញភ្លាម ។

នាយកសហគ្រាស មានសិទ្ធិប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និង ការងារ ពីការមិនសុខចិត្តរបស់ខ្លួន ចំពោះការជូនដំណឹងរបស់អធិការការងារ ។

ការប្តឹងតវ៉ានេះ មិនជំទាស់នឹងមតិយោបល់របស់អធិការការងារដែលបានជូនដំណឹងដល់នាយកសហគ្រាសឡើយ នៅពេលពុំទាន់មានសេចក្តីសំរេចជាផ្លូវការពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និង ការងារ ។

៥ - បទបញ្ជាផ្ទៃក្នុងដែលបានចុះទិដ្ឋាការ ពីអធិការការងារអោយប្រើប្រាស់ជាផ្លូវការហើយនោះ ត្រូវតែបិទទៅទីណាមួយដ៏សមរម្យ អាចចូលទៅមើលបានដោយងាយក្នុងកន្លែងធ្វើការ ហើយនិងនៅមាត់ទ្វារ បន្ទប់សំរាប់ទទួលយកអ្នកស៊ីឈ្នួលអោយធ្វើការ ។

បទបញ្ជាផ្ទៃក្នុងនេះ ត្រូវតែរក្សាទុកដាក់អោយបានល្អ អានបានច្បាស់ជាដរាប ។

៦ - ការកែប្រែគ្រប់យ៉ាងនៃបទបញ្ជាផ្ទៃក្នុង ត្រូវតែអនុវត្តតាមបែបបទ និង នីតិវិធីដូចគ្នា និង ការរៀបចំកសាងបទបញ្ជាផ្ទៃក្នុងដែរ ។

ក្រសួងសង្គមកិច្ច និងការងារ សង្ឃឹមថា នាយក ឬ ម្ចាស់សហគ្រាស គ្រឹះស្ថាន រោងចក្រ ឧស្សាហកម្ម រ៉ែ ពាណិជ្ជកម្ម សិប្បកម្ម សេវាកម្ម ទាំងអស់នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះ អោយបានទាន់ ពេលវេលា និង មានប្រសិទ្ធភាព ខ្ពស់ជាពុំខាន ។

**រដ្ឋមន្ត្រី ក្រសួងសង្គមកិច្ច និង ការងារ**

ហត្ថលេខា

**ស៊ិយ សែម**

*****